## រាជបណ្ឌិត្យសភាកម្ពុជា
## វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ

*អត្ថបទស្រាវជ្រាវ ស្តីពី*

# សញ្ញាណនៃវប្បធម៌វិទ្យា

An Inroduction to Culturology

*ដោយ ប្រេង ពិសិដ្ឋ និង ម៉ិល វាសនា*

ខែកុម្ភៈ ២០២០

# សញ្ញាណនៃវប្បធម៌វិទ្យា

An Inroduction to Culturology

*ដោយ ប្រែង ពិសិដ្ឋ និង ម៉ិល វាសនា*

## សេចក្ដីផ្ដើម

*វប្បធម៌វិទ្យា* (Culturology) ជាបញ្ញត្តិថ្មីមួយសម្រាប់កម្ពុជា ដោយវាពុំទាន់ត្រូវគ្រឹះស្ថានសិក្សា ឬស្ថាបនណាមួយបានសិក្សាមុខវិជ្ជានេះឬបង្កើតផ្នែកនេះនៅឡើយទេ ក្រៅពីរាជបណ្ឌិត្យសភាកម្ពុជា។ យើងក៏ពុំទាន់ឃើញមានឯកសារពន្យល់បកស្រាយអំពីវប្បធម៌វិទ្យាជាភាសាខ្មែរនៅឡើយដែរ។ ការបង្កើតផ្នែកវប្បធម៌វិទ្យានៅរាជបណ្ឌិត្យសភាកម្ពុជាមានប្រយោជន៍ខ្លាំងណាស់សម្រាប់សិក្សាស្រាវជ្រាវពីវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ តែយើងក៏ត្រូវជម្នះបញ្ហាជាច្រើនដែរ ដោយយើងពុំទាន់បានយល់ដឹងស៊ីជម្រៅអំពីវប្បធម៌វិទ្យានៅឡើយ។

នៅបណ្ដាប្រទេសលោកខាងលិចក៏ពុំសូវមានសៀវភៅសរសេរអំពីវប្បធម៌វិទ្យានេះដែរ។ គេប្រើបញ្ញត្តិផ្សេង តែមានខ្លឹមសារប្រហាក់ប្រហែលគ្នា។ គេបង្កើតមុខវិជ្ជា *ការសិក្សាវប្បធម៌* (Cultural Studies) ដែលគេយល់ថាវាដូចគ្នានឹងវប្បធម៌វិទ្យាដែរ។ *ការសិក្សាវប្បធម៌* ក៏សិក្សាស្រាវជ្រាវអំពីវប្បធម៌ ហើយ *វប្បធម៌វិទ្យា* ក៏សិក្សាស្រាវជ្រាវអំពីវប្បធម៌ដែរ។

បញ្ញត្តិ *វប្បធម៌វិទ្យា* មានលំអានសរសេរមកជាបន្តបន្ទាប់ តែមិនមានការបង្កើតជាមុខវិជ្ជាឯកទេសសម្រាប់សិក្សាដូចជាមុខវិជ្ជាដទៃទៀតឡើយ។ ប្រទេសរុស្ស៊ីបានបង្កើតឱ្យមានមុខវិជ្ជា *វប្បធម៌វិទ្យា* នេះ និងដាក់ឱ្យសិក្សានៅតាមមហាវិទ្យាល័យ ដោយមានគោលបំណងសិក្សាច្បាស់លាស់ មានកម្មវិធីសិក្សាត្រឹមត្រូវ រហូតមានការបណ្ដុះបណ្ដាលដល់ថ្នាក់បណ្ឌិត និងក្រោយបណ្ឌិតទៀតផង។

មានការលើកឡើងថា *វប្បធម៌វិទ្យា* ត្រូវប្រទេសរុស្ស៊ីបង្កើតឡើងដើម្បីជំនួសទស្សនវិជ្ជាកុម្មុយនីស្តម៉ាក្ស-លេនីន ដែលបានដួលរលំទៅ។ អត្ថបទនេះនឹងព្យាយាមពន្យល់បកស្រាយអំពីមូលដ្ឋាននៃវប្បធម៌វិទ្យា។

## វប្បធម៌វិទ្យាជាអ្វី?

វប្បធម៌វិទ្យាត្រូវបានកំណត់អត្ថន័យថា ជាមុខវិជ្ជាវិទ្យាសាស្ត្រដែលសិក្សាបកស្រាយពីលំដាប់ផ្សេងគ្នានៃបាតុភូតវប្បធម៌។ បញ្ញត្តិ « វប្បធម៌វិទ្យា » (ជាភាសាអាឡឺម៉ង់ *Kulturologies*) ប្រហែលត្រូវលើកឡើងជាលើកដំបូងនៅឆ្នាំ១៩១៥ ដោយគីមីវិទូទទួលរង្វាន់ណូបែល លោក *វីលហែម អូស្តវ* (Wilhelm Ostwald) នៅក្នុងការបកស្រាយអំពី *ប្រព័ន្ធវិទ្យាសាស្ត្រ*។[១] ក្រោយមកលោក *លេសលី អេ វ៉ាយធ៍* (Leslie A.White) នរវិទូអាមេរិកបានលើកឡើងនូវទ្រឹស្ដីផ្សេងៗអំពីការវិវត្តនៃវប្បធម៌និងការសិក្សាវប្បធម៌តាមបែបវិទ្យាសាស្ត្រ ដែលលោកហៅថា « វប្បធម៌វិទ្យា »។ លោកបានបង្កើតបញ្ញត្តិ « វប្បធម៌វិទ្យា » នេះឡើង ព្រោះលោកជឿថា វប្បធម៌មិនអាចពន្យល់តាម ចិត្តវិទ្យា ជីវវិទ្យា ឬសរីរសាស្ត្របានទេ តែត្រូវពន្យល់តាមលក្ខណៈរបស់វាផ្ទាល់។ មានន័យថា ការពន្យល់បកស្រាយអំពីវប្បធម៌គឺមានតែវប្បធម៌វិទ្យាប៉ុណ្ណោះ។ វប្បធម៌មានវិធីសាស្ត្រស្រាវជ្រាវ មិនមែនគ្រាន់តែជាកម្មវត្ថុនៃការស្រាវជ្រាវប៉ុណ្ណោះទេ។ ដូច្នេះ *វប្បធម៌វិទ្យា* (Culturology) និង *ការសិក្សាវប្បធម៌* (Cultural Studies) មិនមែនខុសគ្នាត្រឹមតែ សព្ទ នោះទេ តែខុសគ្នាខាងវិធីសាស្ត្រផងដែរ។

---

[១] Mikhail Epstein, ***From Culturology to Transculture*** (http://books.google.com/books?isbn=03122 18087...)

*វប្បធម៌វិទ្យា* ជាមុខវិជ្ជាថ្មីមួយដែលបានកើតឡើងនៅរុស្ស៊ីក្រោយការដួលរលំសហភាពសូវៀតនិងបណ្ដារដ្ឋផ្សេងទៀតនៃអតីតប្លុកសូវៀត។ ដោយកំណត់ថា វប្បធម៌វិទ្យាជាការសិក្សាអំពីវប្បធម៌ទាំងឡាយរបស់មនុស្សជាប្រព័ន្ធរួម និងសិក្សាអំពីឥទ្ធិពលរបស់វប្បធម៌លើឥរិយាបថមនុស្ស វាអាចដូចគ្នាទៅនឹងមុខវិជ្ជាមួយនៃបណ្ដាប្រទេសលោកខាងលិច *ការសិក្សាវប្បធម៌* (Cultural Studies) តែយ៉ាងណា វាមានការខុសប្លែកគ្នាលើផ្នែកសំខាន់ៗមួយចំនួន [២] ។ វប្បធម៌វិទ្យាមិនដូចមុខវិជ្ជានរវិទ្យាវប្បធម៌ (Cultural Anthropology) ឬការសិក្សាវប្បធម៌ទាំងស្រុងទេ។ ជាគំនិតរួម ក្នុងអត្ថន័យជាភាសារុស្ស៊ី វប្បធម៌ជាមុខវិជ្ជាដែលមិនអាចបំបែកទៅជាការសិក្សាពិសេសដោយឡែកផ្សេងៗគ្នាបានទេ។ ក្នុងន័យនេះ កម្មវត្ថុសិក្សារបស់វប្បធម៌វិទ្យាគឺវប្បធម៌ជា *ប្រព័ន្ធរួម* នៃវប្បធម៌និងជាតិសាសន៍ អាជីព ពូជសាសន៍ បញ្ញាភេទ ។ល។

លោក *អិបស្ទេន* (Epstein) បានឱ្យនិយមន័យវប្បធម៌វិទ្យារុស្ស៊ីថា ជាការសិក្សាអំពីវប្បធម៌ ជាប្រព័ន្ធរួមមួយនៃវប្បធម៌ទាំងឡាយ ដូចជា ជាតិ អាជីព ពូជសាសន៍ បញ្ញាភេទ . . . ។ល។ ដូច្នេះ តាមនិយមន័យរបស់លោក *អិបស្ទេន* (Epstein) វប្បធម៌វិទ្យាទាមទារឱ្យមានការយល់ដឹងគំនិតរួមនៃវប្បធម៌ ព្រោះវាមានទំនាក់ទំនងទៅនឹងមុខវិជ្ជាផ្សេងទៀតដែលយើងមិនបានដឹង។ ព្រំដែនវប្បធម៌គឺធំទូលាយនិងស៊ីជម្រៅជាងព្រំដែនសង្គម។ ខណៈសង្គមមានតួនាទីក្ដោបលើការរស់នៅរបស់មនុស្សខាងផ្នែកសកម្មភាពនិងអន្តរទំនាក់ទំនង វប្បធម៌ក្ដោបរាល់សកម្មភាពរបស់មនុស្សជំនាន់មុន រួមមាន ស្នាដៃសិល្បៈ របកគំហើញវិទ្យាសាស្ត្រ តម្លៃសីលធម៌ និងអ្វីៗផ្សេងទៀត។ [៣]

បញ្ហាទូទៅរបស់វប្បធម៌វិទ្យាគឺអប់រំឱ្យឆ្លើយនឹងសំណួរថា តើវប្បធម៌កើតឡើងយ៉ាងដូចម្ដេច? តើអ្វីជាមូលដ្ឋាននៃវប្បធម៌? តើអ្វីខ្លះជាសមាសភាពផ្សំនៃវប្បធម៌? តើវប្បធម៌ប្រែប្រួលយ៉ាងដូចម្ដេច? តើវប្បធម៌ទាំងឡាយធ្វើអន្តរកម្មនិងជះឥទ្ធិពលលើគ្នាយ៉ាងដូចម្ដេច? [៤]

មានការលើកឡើងថា វប្បធម៌វិទ្យាមានវិសាលភាពធំជាងមុខវិជ្ជាវិទ្យាសាស្ត្រទស្សនវិជ្ជា ទោះបីជាវាមានការធ្វើទស្សនវិជ្ជាក្ដី។ ជាទស្សនវិស័យរបស់អ្នកវប្បធម៌វិទ្យាឬអ្នកអនាគតនិយម គឺថា បម្រែបម្រួលវប្បធម៌នាំមុខទស្សនវិជ្ជា។ វប្បធម៌ឬសង្គមមានការប្រែប្រួលមុន បន្ទាប់មកទើបទស្សនវិជ្ជាព្យាយាមបកស្រាយ ដែលមានចរឹតបង្ហាញនូវសច្ចភាពនៃបម្រែបម្រួលនោះ។ ដូច្នេះហើយទើបគេយល់ថា ទស្សនវិជ្ជាមិននាំឱ្យមានការប្រែប្រួលសង្គមឬវប្បធម៌ទេ តែវាគ្រាន់តែមានឥទ្ធិពលតិចតួចប៉ុណ្ណោះ។ ប៉ុន្តែអ្នកខ្លះទៀតយល់ថា ទស្សនវិជ្ជានាំឱ្យមានបម្រែបម្រួលវប្បធម៌ ព្រោះការបកស្រាយរបស់ទស្សនវិជ្ជាអំពីអ្វីមួយនឹងនាំមនុស្សទៅរកតម្លៃថ្មី គំនិតថ្មី និងការប្រែប្រួលថ្មី។ ចំពោះបញ្ហានេះ គេអាចនិយាយបានថា រវាងបម្រែបម្រួលវប្បធម៌និងទស្សនវិជ្ជា គឺជាបញ្ហាពងមាន់និងមេមាន់។ [៥]

ពេលដែលវប្បធម៌ជាសាររបស់មនុស្ស វប្បធម៌វិទ្យាគឺជាការយល់ដឹងអំពីវប្បធម៌យ៉ាងច្បាស់លាស់។ វប្បធម៌វិទ្យាគឺសម្រាប់វប្បធម៌ ឯវប្បធម៌គឺសម្រាប់មនុស្សជាតិ ដែលជាមធ្យោបាយនៃចំណេះវិជ្ជានិងការរៀបចំ

---

[២] ***Culturology***, (http://en.wikipedia.org/wiki/Culturology)

[៣] ***POSITION PAPER, 2003, TRANSCULTURE***, (http://arts.monash. edu.au/lcl/research/journals/ trans-2003-epstien-position.pdf)

[៤] Nata B.Krylova, ***Values of Russian Education, What Is Changing and How: Answers to some Philosophical Questions***, (http://www.bu.edu/wcp/Papers/Educ/EducKryl.htm)

[៥] ***Culturologists versus Philosophists? Culturology versus Philosophy?*** (http://futuristguy.wordpress. com/2008/05/17/culturologists-versus-philosophists-culturology-versus-philosophy/)

ខ្លួន។ បើវប្បធម៌បង្កើតឡើងដោយធម្មជាតិ នោះវប្បធម៌វិទ្យាមិនមែនត្រឹមតែជាការសិក្សាវប្បធម៌ទេ គឺវាសិក្សាទាំងការបង្កើតរបស់វានោះទៀត។ វប្បធម៌វិទ្យា គឺជាវិទ្យាសាស្ត្រសិក្សាអំពីបាតុភូតនិងប្រព័ន្ធវប្បធម៌។ វប្បធម៌វិទ្យាគួរមានទីតាំងនៅក្នុងចំណោមវិទ្យាសាស្ត្រទាំងឡាយ ព្រោះវប្បធម៌ជាបាតុភូតមានលក្ខណៈរបស់វាផ្ទាល់ ពោលគឺវាមានដំណើរពិសេសដោយឡែក មានយន្តការនៃការប្រែប្រួល មានរចនាសម្ព័ន្ធ គំរូ និងច្បាប់របស់វាផ្ទាល់ ហើយដែលវប្បធម៌នោះជាមរតកផ្សេងៗគ្នានិងជាស្នាដៃរបស់មនុស្សជាតិ។ [៦]

វប្បធម៌វិទ្យាផ្តល់នូវចំណេះដឹងរួមអំពីផ្នែកផ្សេងៗនៃវប្បធម៌។ វប្បធម៌រួមបញ្ចូលទាំងភាពបុិនប្រសប់វិទ្យាសាស្ត្រ មុខរបរ សិល្បៈ វិជ្ជាជីវៈ និងជំនឿ ដែលផ្នែកទាំងអស់នេះអភិវឌ្ឍនៅក្នុងវិស័យរបស់វាផ្ទាល់ ហើយមិនសូវយល់ដឹងពីផ្នែកផ្សេងទៀត។ វប្បធម៌វិទ្យាត្រូវយល់ដឹងលក្ខណៈពិសេសនៃភាពរួមវប្បធម៌ នៅពេលភាពដោយឡែកនៃវិស័យទាំងឡាយត្រូវផ្សារភ្ជាប់ឱ្យមានទំនាក់ទំនងគ្នា។

ក្រៅពីអត្ថន័យដែលបានបង្ហាញខាងលើ គេឃើញមាននិយមន័យវប្បធម៌វិទ្យាពីរប្រហាក់ប្រហែលគ្នា ទី១ វប្បធម៌វិទ្យាជាក្រុមនៃមុខវិជ្ជាផ្សេងៗ រួមមាន ទ្រឹស្តីអក្សរសាស្ត្រ សង្គមវិជ្ជាវប្បធម៌ សាសនាឬទស្សនវិជ្ជា ទស្សនវិជ្ជាប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រនយោបាយ សោភ័ណវិជ្ជា ជាដើម។ វាមានលក្ខណៈជាការប្រៀបធៀបនិងជាការសិក្សាក្នុងវប្បធម៌ទូទៅ។ ទី២ វប្បធម៌វិទ្យាជាអធិប្រព័ន្ធ(meta-system) ឬជាអធិវិទ្យាសាស្ត្រ (meta-science) ជាទស្សនវិជ្ជាវប្បធម៌ថ្មីដែលជួយពន្យល់អំពីការរីកចម្រើននៅទូទាំងពិភពលោក។ *អ៊ី អា ឡឺវ៉ាស* (I. A. Levâš) ជាអ្នកនិពន្ធជាតិបេឡារុស បានលើកឡើងថា « ប្រសិនបើវិទ្យាសាស្ត្រវប្បធម៌ជាក្រុមនៃមុខវិជ្ជាផ្សេងៗដែលសិក្សាពីលោកធាតុទាក់ទងនឹងវប្បធម៌ផ្សេងៗដោយគ្មានដែនកំណត់ នោះវប្បធម៌វិទ្យាគឺជាច្បាប់នៃកម្លាំងស្រូបទាញមុខវិជ្ជាទាំងនោះបញ្ចូលគ្នា។ ជារួម វាជាទស្សនវិជ្ជាវប្បធម៌» ។ [៧]

## វប្បធម៌វិទ្យា និង ការសិក្សាវប្បធម៌

*វប្បធម៌វិទ្យា* និង *ការសិក្សាវប្បធម៌* បានបង្កើតឡើងស្ទើរតែដំណាលគ្នា ជាការលោតសន្ទឹងនៃតម្រូវការនិងអាទិភាពទ្រឹស្តីផ្សេងៗរបស់វប្បធម៌។ សម្រាប់បណ្តាប្រទេសនិយាយភាសាអង់គ្លេស គេស្គាល់បញ្ញត្តិ *ការសិក្សាវប្បធម៌* (Cultural Studies) តែនៅរុស្ស៊ីគេប្រើបញ្ញត្តិ *វប្បធម៌វិទ្យា* ។ ដើម្បីបង្ហាញពីចំណុចស្របគ្នានិងខុសគ្នារវាង *វប្បធម៌វិទ្យា* និង *ការសិក្សាវប្បធម៌* យើងនឹងលើកយកលក្ខណៈសំខាន់៥នៃ *ការសិក្សាវប្បធម៌* ដែលលើកឡើងដោយ *ហ្ស៊ីយ៉ូឌីន សារដារ* (Ziauddin Sardar) ក្នុងសៀវភៅ *មូលដ្ឋាននៃការសិក្សាវប្បធម៌* (*Introducting Cultural Studies*) មកពិចារណា៖ [៨]

១- *ការសិក្សាវប្បធម៌* មានគោលបំណងពិនិត្យខ្លឹមសារក្នុងន័យប្រតិបត្តិវប្បធម៌និងទំនាក់ទំនងរបស់វាទៅនឹងអំណាច។ *វប្បធម៌វិទ្យា* មានគោលបំណងពិនិត្យវប្បធម៌ជាមជ្ឈមណ្ឌលនៃការអនុវត្ត ដែលអាចរំដោះមនុស្សចេញពីស្ថានភាពបែបធម្មជាតិនិងស្ថានភាពពឹងផ្អែកលើរូបកាយ ស្ថានភាពដែលអ្នកខ្សោយពឹងលើអ្នកខ្លាំង ដែលនោះជាទំនាក់ទំនងអំណាច។ វប្បធម៌ជាអ្វីៗដែលបង្កើតឡើងដោយ

---

[៦] Akifumi Iwabuchi, ***Marine Culturology***, Tokyo University of Marine Science & Technology, 2010. (www. soi.wide.ad.jp/class/20090061/ materials_for_student/03/20090061-03-2in1.pdf)

[៧] Marlène Laruelle, ***The Discipline of Culturology: A New 'Ready-Made Thought' for Russia***, 2004 (www. sagepublications.com)

[៨] Mikhail Epstein, ***From Culturology to Transculture*** (http://books.google.com/books?isbn=03122 18087...)

មនុស្ស និងជាអ្វីៗដែលបង្កើតមនុស្សឱ្យខុសពីធម្មជាតិសរីរាង្គ និងមិនអាចបំពេញមកជាធម្មជាតិសរីរាង្គបាន។

២- *ការសិក្សាវប្បធម៌* មិនមែនជាការសិក្សាដាច់ដោយឡែកពីបរិបទនយោបាយឬសង្គមនោះទេ។ វាមានគោលបំណងយល់ដឹងអំពីវប្បធម៌នូវរាល់ទម្រង់ស្មុគស្មាញទាំងអស់ និងមានបំណងវិភាគបរិបទសង្គមនិងនយោបាយដែលបានបង្ហាញឡើងតាមវប្បធម៌។ វប្បធម៌មានអត្ថិភាពនៅក្នុងបរិបទសង្គមនិងនយោបាយ តែបរិបទនេះវាគ្រាន់តែជាទិដ្ឋភាពមួយផ្នែកនៃវប្បធម៌ប៉ុណ្ណោះ វាមិនគ្របដណ្ដប់វប្បធម៌ទាំងមូលឡើយ។ ស្នាដៃសិល្បៈនិងទស្សនវិជ្ជា ក្បួនរីត៍និងការអនុវត្តខាងស្មារតី តម្លៃសីលធម៌ ទំនាក់ទំនងផ្ទាល់ខ្លួន ការប្រត្តិបត្តិប្រចាំថ្ងៃមានទំនាក់ទំនងនឹងបម្រែបម្រួលនិមិត្តរូប ជាទិដ្ឋភាពនៃវប្បធម៌ដែលធ្វើឱ្យមនុស្សមិននៅត្រឹមតែជាសត្វចេះធ្វើនយោបាយឡើយ។ វប្បធម៌វិទ្យាមានតួនាទីបង្ហាញវប្បធម៌ជាភាពសរុបដ៏ទូលំទូលាយ ដែលផុតហួសពីផ្នែកដោយឡែកណាមួយ រួមទាំងនយោបាយផងដែរ។ *វប្បធម៌វិទ្យា* មានការយល់ដឹងវប្បធម៌ដោយខ្លួនឯង។ បេសកកម្មរបស់វាមិនមែនដើម្បីគ្រប់គ្រងវប្បធម៌ដោយប្រើស្ថាបនអំណាច ដូចនយោបាយបានធ្វើនោះទេ តែជាការគ្រប់គ្រងញាណរបស់វាដោយខ្លួនឯង។

៣- នៅក្នុង *ការសិក្សាវប្បធម៌* វប្បធម៌មានមុខងារពីរយ៉ាងគឺ ជាកម្មវត្ថុនៃការសិក្សាផង និងជាទីកន្លែងនៃសកម្មភាពនយោបាយនិងការរិះគន់ផង។ *ការសិក្សាវប្បធម៌* មានបំណងក្លាយជាគំនិតប្រតិបត្តិជាក់ស្តែងផងនិងជាផ្នែកគំនិតបញ្ញាផង។ *វប្បធម៌វិទ្យា* ក៏មានមុខងារទាំងពីរនេះដូច *ការសិក្សាវប្បធម៌* ដែរ តែវាមិនបង្ហាញវប្បធម៌ជាចំណុចនៃការរិះគន់ និងសកម្មភាពនយោបាយទេ តែវាបង្ហាញចំណុចផ្លាស់ប្តូរជាអចិន្ត្រៃយ៍នៃការប្រតិបត្តិនយោបាយ តាមរយៈការធ្វើបរិបទនីយកម្មនៃបរិបទជានិមិត្តរូបរបស់វា។ វប្បធម៌វិទ្យាមិនអនុញ្ញាតមុខវិជ្ជាដោយឡែកណាមួយមានបុព្វសិទ្ធិលើមុខវិជ្ជាដទៃ និងដើរតួជាពាក្យសព្ទចុងក្រោយ ឬជាមូលដ្ឋានសាកលនៃការបកស្រាយឡើយ។ វប្បធម៌វិទ្យាមិនមែនជាគំនិតប្រតិបត្តិ *(pragmatic enterprise)* ស្របទៅតាមគំរូសកម្មភាពវប្បធម៌ផ្សេងៗឡើយ។

៤- *ការសិក្សាវប្បធម៌* មានបំណងបង្ហាញនិងសម្របសម្រួលការបែងចែកពុទ្ធិ សំដៅលុបបំបាត់ការបែងចែករវាងទម្រង់ពុទ្ធិបែបកាត់យល់(ពុទ្ធិអព្ភន្តរញាណដែលផ្អែកលើវប្បធម៌ក្នុងតំបន់) និងទម្រង់ពុទ្ធិបរានុម័ត (ពុទ្ធិសាកល)។ វាសន្មតពីអត្តសញ្ញាណរួមនិងផលប្រយោជន៍រវាងអ្នកចេះនិងអ្វីដែលគេចេះ រវាងអ្នកអង្កេតពិនិត្យនិងអ្វីដែលគេកំពុងអង្កេតពិនិត្យ។ ក្នុងគោលបំណងដើម្បីលុបបំបាត់ការបែងចែកពុទ្ធិនិងភាពខុសគ្នានៃឯកទេសកម្ម វប្បធម៌វិទ្យាសហការយ៉ាងជិតស្និទ្ធជាមួយការសិក្សាវប្បធម៌។ វប្បធម៌វិទ្យាព្យាយាមខិតជិតវប្បធម៌ដោយសព្វរបស់វា និងព្យាយាមអភិវឌ្ឍភាសារួមមួយដែលជៀសវាងការឆ្លងហួសទៅរកនយោបាយនិយម វិទ្យាសាស្ត្រនិយម សោភ័ណនិយម សីលធម៌និយម ឬដាច់ខាតនីយកម្មនៃទិដ្ឋភាពវប្បធម៌ដោយឡែកណាមួយ។ នេះជាមូលហេតុដែលវប្បធម៌វិទ្យាមិនសង្កត់ធ្ងន់លើវប្បធម៌តាមនយោបាយ ដែលការអង្កេតលើវប្បធម៌តាមនយោបាយនេះបានប្រើយ៉ាងលើសលប់នៅក្នុងការសិក្សាវប្បធម៌ ។ ប្រសិនបើអ្នកឯកទេសទាំងអស់ធ្វើការងារនៅក្នុងមុខវិជ្ជារបស់ខ្លួនឬវិស័យវប្បធម៌ទៅតាមច្បាប់និងបម្រាមដោយឥតដឹងខ្លួន នោះអ្នកវប្បធម៌វិទ្យាធ្វើឱ្យវប្បធម៌ទៅជាកម្មវត្ថុនិយមន័យ ហើយដោយហេតុនោះគឺវាហួសដែនកំណត់របស់វា។

៥- *ការសិក្សាវប្បធម៌* សង្កត់ធ្ងន់លើរង្វាយតម្លៃសីលធម៌ សង្គមទំនើប និងលើមាគ៌ាមូលដ្ឋាន (radical line) នៃសកម្មភាពនយោបាយ។ គោលការណ៍របស់ការសិក្សាវប្បធម៌មិនមែនជាការសិក្សាគ្មាន

តម្លៃទេ តែវាសង្កត់ធ្ងន់លើការកសាងសង្គមដោយការផ្សារភ្ជាប់នឹងនយោបាយ។ ដូច្នេះ ការសិក្សាវប្បធម៌ព្យាយាមយល់និងកែប្រែរចនាសម្ព័ន្ធនៃការគ្របដណ្តប់នៅគ្រប់ទីកន្លែង លើកលែងតែសង្គមមូលធនឧស្សាហកម្ម។ វប្បធម៌វិទ្យាមិនមែនជាទម្រង់ប្រឆាំងខាងនយោបាយទេ។ វាមិនរិះគន់នយោបាយវប្បធម៌មួយក្នុងនាមវប្បធម៌មួយទៀត ដែលជានយោបាយមានការរីកចម្រើននិងជឿនលឿនជាងនោះទេ។ វារិះគន់លើនយោបាយពីទស្សនៈវប្បធម៌ទាំងមូល ជាប្រភេទនៃការពិភាក្សា ជាទំនាក់ទំនងនៃអំណាច ជាការអនុវត្តតូចចង្អៀត។ វប្បធម៌វិទ្យាមិនមែនជាបញ្ហាការប្រឆាំងទេ តែជាបញ្ហាអតិសេដ្ឋភាព ជារបៀបហួសការប្រតិបត្តិឬទ្រឹស្តីប្រើសមត្ថភាពនិមិត្តសញ្ញាវប្បធម៌ និងភាពស្មុកស្មាញឥតដែនកំណត់របស់វា។

## វប្បធម៌វិទ្យា និង អន្តរវប្បធម៌

ទោះបីវប្បធម៌វិទ្យាជាមុខវិជ្ជាវិទ្យាសាស្ត្រក្តី តែវាមានលទ្ធភាពនាំទៅហួសវិស័យសិក្សាវិទ្យាសាស្ត្រនេះ គឺទៅជាការអនុវត្តពិតប្រាកដដែលយើងហៅថា *អន្តរវប្បធម៌* (transcultural)។ អន្តរវប្បធម៌ជាវិធីមួយទៅហួសវប្បធម៌ដែលយើងមាន និងជាវិធីប្រើកម្លាំងផ្លាស់ប្តូរវប្បធម៌ចំពោះវប្បធម៌ខ្លួនឯង។ អន្តរវប្បធម៌ជាលំដាប់ទីពីរនៃលក្ខណៈវប្បធម៌ ដែលវាមានសមត្ថភាពបណ្តុះខ្លួនឯងនិងអតិសេដ្ឋភាពខ្លួនវា។ ប្រសិនបើវប្បធម៌វិទ្យាយល់ដឹងពីវប្បធម៌ នោះអន្តរវប្បធម៌ជាបម្រែបម្រួលវប្បធម៌ ជាភាពរួមនៃទ្រឹស្តីនិងការប្រតិបត្តិ ដែលរំដោះវប្បធម៌ពីយន្តការគ្រប់គ្រងផ្ទាល់របស់ខ្លួនវា។ តាមរយៈការទៅហួសព្រំដែនវប្បធម៌ធម្មជាតិឬកម្រិតដំបូង ទិដ្ឋភាពផ្លាស់ប្តូរវប្បធម៌បាននាំមនុស្សទៅរកសេរីភាពជាបន្តបន្ទាប់ ឱ្យចាកផុតពីភាពចំណុះនិមិត្តសញ្ញា ការងប់ងុលនឹងមនោគមវិជ្ជា ការងប់នឹងស្នេហាជាតិ ដែលជាលក្ខណៈរបស់យើង ក្នុងនាមជាសមាជិកក្រុមវប្បធម៌មួយ។ អន្តរវប្បធម៌អាចកំណត់អត្ថន័យថា ជាប្រព័ន្ធចំហនៃជម្រើសនិមិត្តសញ្ញាផ្សេងៗ ទៅរកវប្បធម៌មានស្រាប់និងប្រព័ន្ធសញ្ញាដែលវាបង្កើតឡើង។

*អិបស្តេន* (Epstein) បានលើកឡើងថា នៅក្នុងពិភពអន្តរវប្បធម៌ វប្បធម៌ទាំងឡាយធ្វើឱ្យភាវៈសង្គមមានសេរីភាពរួចផុតពីសង្គម។ មានន័យថា ភាពខុសៗគ្នានៃវប្បធម៌បានរំដោះបុគ្គលចេញពីមនោគមវិជ្ជាវប្បធម៌និងការប្រតិបត្តិវប្បធម៌។ ការអប់រំអំពីអន្តរវប្បធម៌ជាភាវៈហួសពីទម្រង់អត្តិភាពជាក់លាក់មួយឬជាការរកឃើញទីតាំងមួយនៅត្រង់ព្រំដែនវប្បធម៌ទាំងឡាយដែលមានអត្តិភាព។ ទោះបីជាអន្តរវប្បធម៌ធ្វើឱ្យបុគ្គលម្នាក់ៗ ឃ្លាតចេញពីអត្តសញ្ញាណនៃវប្បធម៌ដោយឡែកៗរបស់ពួកគេក្តី នៅកម្រិតមួយផ្សេងទៀត វាជាដំណើរអន្តរកម្មរវាងវប្បធម៌ផ្សេងៗ ដែលបុគ្គលម្នាក់ៗមើលឃើញថា ខ្លួនស្ថិតនៅក្រៅវប្បធម៌ដោយឡែកមួយ នៅក្រៅដែនកំណត់ជាតិ ពូជសាសន៍ បញ្ហាភេទ មនោគមវិជ្ជា និងដែនកំណត់ដទៃទៀត។

## វប្បធម៌វិទ្យា និង សង្គមវិជ្ជា

ខុសពីសង្គមវិជ្ជាដែលសិក្សាពីបាតុភូតសង្គម វប្បធម៌វិទ្យាសិក្សាពីបាតុភូតវប្បធម៌និងប្រព័ន្ធវប្បធម៌ ព្រោះវប្បធម៌ជាបាតុភូតមានលក្ខណៈរបស់វាផ្ទាល់ ដែលមានដំណើរពិសេសដោយឡែក មានយន្តការប្រែប្រួល មានរចនាសម្ព័ន្ធ គំរូ និងច្បាប់របស់វាផ្ទាល់។ ហេតុនេះ វប្បធម៌វិទ្យាគួរតែមានកន្លែងមួយក្នុងចំណោមមុខវិជ្ជាវិទ្យាសាស្ត្រទាំងឡាយ។ *អូហ្គុស កុមត៍* (August Comte) បានលើកឡើងថា ដោយសារវប្បធម៌ (មិនមែនជាជីវិតសង្គម) ជាសមិទ្ធផលនិងមត៌កមនុស្សជាតិដ៏អស្ចារ្យ វប្បធម៌វិទ្យាគួរចាត់ទុកជាវិទ្យាសាស្ត្រក្នុងលំដាប់កំពូលនៃឋានានុក្រមវិទ្យាសាស្ត្រ។

លោក *វិនសាន ហ៊ាំង* (Wen-shan Huang) បានគាំទ្រនិងជំរុញឱ្យវប្បធម៌វិទ្យាទៅជាមុខវិជ្ជាឯករាជ្យមួយ សិក្សាពីបាតុភូតវប្បធម៌ដោយប្រើវិធីសាស្ត្រប្រវត្តិសាស្ត្រវប្បធម៌។ លោកបានលើកឡើងថា ប្រព័ន្ធវប្បធម៌ត្រូវសិក្សាដោយវិទ្យាសាស្ត្រវប្បធម៌វិទ្យា ហើយប្រព័ន្ធសង្គមសិក្សាដោយសង្គមវិជ្ជា។ លោកបានលើកហេតុផលចំពោះចំណុចនេះដូចខាងក្រោម៖ [៩]

- វប្បធម៌វិទ្យាជាវិទ្យាសាស្ត្រថ្មីមួយដែលកើតចេញពីសង្គមវិជ្ជា
- មូលហេតុធំបំផុតគឺថា រចនាសម្ព័ន្ធនៃប្រព័ន្ធវប្បធម៌ខុសពីរចនាសម្ព័ន្ធនៃប្រព័ន្ធសង្គម។ ប្រព័ន្ធវប្បធម៌ជាខ្លឹមសារ ឯប្រព័ន្ធសង្គមជាទម្រង់។ (ខ្លឹមសារ) វប្បធម៌របស់គ្រួសារ រដ្ឋ គណបក្សនយោបាយ សាកលវិទ្យាល័យ ឬក្រុមហ៊ុនមួយ គឺកើតឡើងពីតម្លៃនិងខ្លឹមសាររបស់ភាសា វិទ្យាសាស្ត្រ សាសនា សោភ័ណវិជ្ជា ក្រមសីលធម៌ នយោបាយ សេដ្ឋកិច្ច ទស្សនវិជ្ជា ច្បាប់ និងបច្ចេកវិទ្យា។ តម្លៃវប្បធម៌គឺមាននៅក្នុងគ្រប់ក្រុមទាំងអស់ ហើយក្លាយជាភ្នាក់ងារដ៏មានឋាមពល ឬ ជាមធ្យោបាយនៃអត្ថិភាពរបស់ក្រុមទាំងនោះ។ ប្រព័ន្ធសង្គមឬក្រុមសង្គម ដូចជា រដ្ឋឬក្រុមហ៊ុន គឺជាទម្រង់អង្គភាពដែលកំណត់ដោយច្បាប់និងក្រមសីលធម៌។
- ប្រព័ន្ធវប្បធម៌និងដំណើរវប្បធម៌មានជីវិតរបស់វាផ្ទាល់ ដែលកំណត់ដោយច្បាប់របស់វា។ ដូច្នេះ ការសិក្សាអំពីវប្បធម៌ត្រូវក្លាយជាវិទ្យាសាស្ត្រឯករាជ្យដោយមានគោលបំណង កម្រិត ដែនកំណត់ និងច្បាប់របស់វាផ្ទាល់ដោយចៀសមិនរួច។

តាម *ពីទ្រីម អេ ស្សូរគីន* (Pitrim A. Sorokin) រាល់ទ្រឹស្តីបង្ហាញថា បាតុភូតសង្គមនិងបាតុភូតវប្បធម៌មានលក្ខណៈខុសគ្នាទាំងស្រុង ដែលត្រូវសិក្សាដោយឡែកពីគ្នា។ តថភាពវប្បធម៌សិក្សាដោយវិទ្យាសាស្ត្រវប្បធម៌វិទ្យា ហើយបាតុភូតសង្គមសិក្សាដោយសង្គមវិជ្ជា។

បញ្ញត្តិ « វប្បធម៌វិទ្យា » ត្រូវបានប្រើជាលើកដំបូងដោយ *វីលហេម អូសវ៉ាលដ៍* (Wilhelm Ostwald) ជាគីមីវិទូនិងទស្សនវិទូអាឡឺម៉ង់ ដើម្បីសិក្សាអំពីបាតុភូតវប្បធម៌។ លោកបានប្រើសព្ទ *Kulturologie* នៅក្នុងអត្ថបទរបស់លោកនាដើមឆ្នាំ១៩០៩ ហើយបានប្រើវាច្រើនទៀតនៅក្នុងអត្ថបទក្រោយៗមកទៀតរបស់លោក។ លោក *អូសវ៉ាលដ៍* (Ostwald) ប្រហែលជាអ្នកប្រាជ្ញដំបូងគេដែលបានបង្កើតទស្សនៈគោលការណ៍និងគំនិត និងដែនកំណត់វិទ្យាសាស្ត្រវប្បធម៌ខុសពីសង្គមវិជ្ជា ហើយញែកវប្បធម៌វិទ្យាចេញពីសង្គមវិជ្ជា។ លោកបានលើកឡើងថា សព្ទ *សង្គមវិជ្ជា* មានភាពទូលំទូលាយពេក ដោយវាផ្តោតទៅលើអន្តរកម្មសង្គមដែលរួមបញ្ចូលនូវគ្រប់ចំពួកមានជីវិត។ សង្គមនិងវប្បធម៌គឺមិនដូចគ្នាទេ។ *អូសវ៉ាលដ៍* (Ostwald) អាចជាទស្សនវិទូដែលបានបង្ហាញយើងច្បាស់លាស់ជាងទស្សនវិទូផ្សេងទៀត ដែលថា វប្បធម៌វិទ្យាគួរជាវិទ្យាសាស្ត្រឯករាជ្យមួយផ្សេងពីសង្គមវិជ្ជា។ លោកបានលើកបញ្ជាក់ថា ការទទួលស្គាល់និងការពណ៌នាបាតុភូតវប្បធម៌ គឺខុសគ្នាពីការសិក្សានិងការពណ៌នាអន្តរកម្មសង្គម។

នៅក្នុងស្នាដៃរបស់ *លេសលី អេ វ៉ាយធ៍* (Leslie A. White) អំពី *វិទ្យាសាស្ត្រវប្បធម៌៖ ការសិក្សាអំពីមនុស្សនិងអរិយធម៌ (The Science of Culture: A Study of Man and Civilization*, New York, 1939) លោកបានបង្កើតឱ្យមានកូននៅក្នុងគ្រួសារនៃវិទ្យាសាស្ត្រវប្បធម៌វិទ្យា។ លោកបានលើកឡើងថា វប្បធម៌ជារចនាសម្ព័ន្ធនៃព្រឹត្តិការណ៍និងអ្វីៗទាំងឡាយដែលផ្អែកលើភាសានិមិត្តសញ្ញា ប្រពៃណី ឧបករណ៍ ជំនឿ ។ល។ ដែលត្រូវ

[៩] Pitrim A. Sorokin, ***Sociological Theories of Today***, New York: Harper and Row, 1966, pp. 388-391.

ពិចារណានៅក្នុងបរិបទក្រៅរូបកាយ ជាដំណើរនៃលក្ខណៈរបស់វាផ្ទាល់ដែលនៅក្រៅខ្លួនមនុស្ស។ ដូច្នេះ វប្បធម៌វិទ្យាជាការសិក្សាបែបវិទ្យាសាស្ត្រនិងការប្រមូលផ្តុំបាតុភូតវប្បធម៌ដោយខ្លួនវា។ ប្រវត្តិវិទូ *អេច អ៊ី បាណែស* (H. E. Barnes) បានចាត់ទុក *វ៉ាយត៍* (White) ជាបិតាវប្បធម៌វិទ្យា។

*វប្បធម៌* ខុសគ្នាពី *សង្គម* ដែលទាមទារនូវវិទ្យាសាស្ត្រដោយឡែកមួយដើម្បីសិក្សាវា។ គេមិនអាចពន្យល់វប្បធម៌តាមអ្វីផ្សេងក្រៅពីវាខ្លួនវានោះទេ។

វប្បធម៌វិទ្យាគួរមានវិស័យនិងដែនកំណត់ដូចខាងក្រោម៖ [១០]

- ដោយផ្អែកលើទិន្នន័យពិសោធពីនរវិទ្យា សង្គមវិជ្ជា ជាតិពន្ធុវិទ្យា ចិត្តវិទ្យារូបសាស្ត្រវប្បធម៌ ជីវវិទ្យា ប្រវត្តិនិងភូមិសាស្ត្រវប្បធម៌ មុនដំបូងបង្អស់ វប្បធម៌វិទ្យាព្យាយាមបកស្រាយពីប្រភពវប្បធម៌របស់មនុស្សនៅលើពិភពលោកនេះ
- វប្បធម៌វិទ្យាបង្ហាញពីប្រភពនិងការរីកចម្រើនរបស់រចនាសម្ព័ន្ធវប្បធម៌និងស្ថាបនវប្បធម៌គ្រប់ទម្រង់
- វប្បធម៌វិទ្យាសិក្សាពីកំណើត ការរីកចម្រើន ការធ្លាក់ចុះ និងការកើតឡើងវិញរបស់វប្បធម៌និងអរិយធម៌
- វប្បធម៌វិទ្យាបកស្រាយពីការចាប់ផ្តើម ឥទ្ធិពលគ្របដណ្តប់ និងការធ្លាក់ចុះនៃមនោគមវិជ្ជា ទស្សនវិជ្ជា និងសាសនា ដែលមានឥទ្ធិពលលើសកម្មភាពវប្បធម៌នៅដំណាក់កាលផ្សេងៗនៃការវិវត្តវប្បធម៌
- វប្បធម៌វិទ្យាពិនិត្យអង្កេតលើទ្រឹស្តីការវិវត្តវប្បធម៌ និងព្យាយាមដោះស្រាយបញ្ហាបម្រែបម្រួលនៃវប្បធម៌
- វប្បធម៌វិទ្យាសិក្សាអំពីបញ្ហាទាំងឡាយនៃប្រភេទវប្បធម៌ចេញពីទស្សនៈដោយឡែកៗ
- វប្បធម៌វិទ្យាព្យាយាមប្រៀបធៀបប្រព័ន្ធវប្បធម៌លោកខាងកើតនិងលោកខាងលិច និងសិក្សាពីបញ្ហានៃការរួមចូលគ្នារបស់វា
- វប្បធម៌វិទ្យាផ្តោតលើការរីកចម្រើននិងការប្រតិបត្តិវិធីសាស្ត្រថ្មីសម្រាប់ការគិតខាងវប្បធម៌ ដែលនាំហួសពីទស្សនៈមួយទៅជាប្រព័ន្ធនៃការគិតមួយ ពីប្រព័ន្ធទៅក្រុមនៃប្រព័ន្ធ ទៅសំយោគ និងពីសំយោគទៅការផ្លាស់ប្តូរទាំងស្រុងជាចុងក្រោយ។ អាចនិយាយបានថា ជាវិធីសាស្ត្រនៃការរួមគ្នាបញ្ចូលរវាងគំនិតនិងសកម្មភាពដែលមានការឆ្លើយតបចំពោះដំណោះស្រាយលើការប្រែប្រួលឥតឈប់ឈរនៃគ្រប់កម្រិតវប្បធម៌។
- ដូច្នេះ វប្បធម៌វិទ្យាព្យាយាមស្វែងរកនិងបង្កើតច្បាប់អភិវឌ្ឍវប្បធម៌ ទាំងចំពោះដំណាក់កាលទូទៅនៃការវិវត្តវប្បធម៌ ទាំងចំពោះដំណាក់កាលដោយឡែក ស្ថាបនដោយឡែក និងអាចប្រជាជាតិដោយឡែកៗ។
- វប្បធម៌វិទ្យាអាចបង្រួបបង្រួមវិទ្យាសាស្ត្រទាំងអស់ដោះស្រាយវប្បធម៌សាកលលោក និងបង្ហាញពីរបៀបដែលវាពិចារណាលើបញ្ហានៅឋិតថេរនៃអរិយធម៌។

សរុបមក តួនាទីរបស់អ្នកវប្បធម៌វិទ្យាមិនមែនគ្រាន់តែស្វែងរកការពន្យល់ពីទំនាក់ទំនងហេតុផលចំពោះច្បាប់និងទំនោរនៃការរីកចម្រើនវប្បធម៌របស់មនុស្សជាតិនោះទេ តែនៅក្នុងទិដ្ឋភាពប្រតិបត្តិ អ្នកវប្បធម៌វិទ្យាក៏អាចបង្កើតនិងកំណត់ព្រឹត្តិការណ៍នៅក្នុងពិភពបាតុភូតដែរ។

---

[១០] Wen-shan Huang, ***Culturology_Its Evolution and Prospects: An Integral Theory of Culture***, pp.16-17. (www.search.nioerar.edu.tw/edu_paper/data_image/g0000549/0n27/196901/p0000001.pdf)

វប្បធម៌វិទ្យាអាចប្រើវិធីសាស្ត្រមួយចំនួនដូចខាងក្រោម ៖ [១១]

• ជាក់ស្តែងណាស់ គេតែងឃើញមានបាតុភូតវប្បធម៌នៅរួមគ្នាជាមួយបាតុភូតសង្គមនិងបាតុភូតចិត្តសាស្ត្រ និងការពឹងអាស្រ័យគ្នាទៅវិញទៅមករវាងបាតុភូតវប្បធម៌ បាតុភូតសង្គម និងបាតុភូតចិត្តសាស្ត្រ។ ជាវិធីសាស្ត្រនិងវិទ្យាសាស្ត្រ គេអាចបង្រួមបាតុភូតវប្បធម៌ ហើយចាត់ទុកវាឯករាជ្យពីសព៌ាង្គកាយដែលវាអាស្រ័យ។

• វប្បធម៌បច្ចុប្បន្នកាន់តែត្រូវការទំនាក់ទំនង ការយល់ដឹងរវាងមុខវិជ្ជាឯកទេសផ្សេងៗ។ ដើម្បីធ្វើអព្យាក្រឹតកម្មទំនោរពុទ្ធិផ្សេងៗ វប្បធម៌វិទ្យាដែលជាវិទ្យាសាស្ត្រឯករាជ្យមួយ អាចទទួលវិធីសាស្ត្រមួយដែលបង្កើតឡើងដើម្បីផ្តល់នូវទំនាក់ទំនងរវាងមុខវិជ្ជាឯកទេសផ្សេងៗ។

## មុខវិជ្ជាវិទ្យាសាស្ត្រ «វប្បធម៌វិទ្យា»

ទោះបី *វប្បធម៌វិទ្យា* ជាវិទ្យាសាស្ត្រនិងជាបញ្ញត្តិដែលបង្កើតឡើងដោយអ្នកប្រាជ្ញបស្ចិមប្រទេសក្តី តែគេសង្កេតឃើញ *វប្បធម៌វិទ្យា* ត្រូវបានបង្កើតជាមុខវិជ្ជាសិក្សានៅប្រទេស ដែលធ្លាប់គ្រប់គ្រងដោយរបបកុម្មុយនីស្តខណៈដែលនៅបស្ចិមប្រទេសបង្កើតមុខវិជ្ជា *ការសិក្សាវប្បធម៌* (Cultural Studies)។ វប្បធម៌វិទ្យាជាមុខវិជ្ជាវិទ្យាសាស្ត្រក្មេងខ្ចីមួយ ដែលប្រសូតឡើងនៅសតវត្សទី ២០ ។ វប្បធម៌វិទ្យាត្រូវបានបង្កើតជាមុខវិជ្ជាសិក្សាមួយសម្រាប់និស្សិតមហាវិទ្យាល័យនិងនិស្សិតក្រោយឧត្តមសិក្សា ឱ្យសិក្សាអំពីប្រវត្តិវប្បធម៌និងទ្រឹស្តីវប្បធម៌។ មុខវិជ្ជានេះផ្តល់ចំណេះដឹងទូទៅអំពីសារជាតិនិងដែនកំណត់របស់វប្បធម៌វិទ្យា វិធីក្នុងការសិក្សាពីតថភាពសង្គម និងសិក្សាពីបញ្ហាសំខាន់ៗរបស់វប្បធម៌វិទ្យា។

គោលបំណងនៃមុខវិជ្ជានេះគឺដើម្បីបង្ហាញនិស្សិតអំពីបាតុភូតផ្សេងៗ និងទំនោរជីវិតស្មារតីទាំងឡាយនៃសង្គមទំនើប ដោយរួមទាំងសង្គមរុស្ស៊ីផង ដើម្បីបង្រៀនពួកគេឱ្យយល់ និងផ្តល់តម្លៃដល់ភាពដោយឡែកនៃការអភិវឌ្ឍវប្បធម៌នៅក្នុងស្ថានភាពប្រវត្តិសាស្ត្រថ្មី។ វប្បធម៌វិទ្យាដើរតួនាទីជាអស្តិមុខវិជ្ជា (metadiscipline) នៅក្នុងមុខវិជ្ជាសង្គម ដោយមានបំណងប្រមូលផ្តុំនូវបាតុភូតវប្បធម៌ទាំងឡាយ ដែលសិក្សាដោយទស្សនវិជ្ជា ប្រវត្តិវិទ្យា សង្គមវិជ្ជា អក្សរសាស្ត្រ និងការរិះគន់ជាលក្ខណៈសិល្បៈ។ វប្បធម៌វិទ្យាគឺជាផ្នែករួមនិងជាធាតុចាំបាច់មួយនៅក្នុងកម្មវិធីសិក្សានៅសាកលវិទ្យាល័យនៅរុស្ស៊ី។ មុខវិជ្ជាថ្មីនេះបានចូលមកជំនួសកន្លែងរបស់មុខវិជ្ជាម៉ាក្ស-លេនីនឬរូបធាតុនិយមបដិសំយោគ ហើយកំពុងបង្ហាញពីភាពមោះមុតរបស់ខ្លួនដើម្បីផ្តល់វិធីគិតថ្មីអំពីពិភពលោក និងជួយប្រជាជនឱ្យយល់ពីការរីកចម្រើននាពេលបច្ចុប្បន្ន និងតួនាទីរបស់រុស្ស៊ីនៅក្នុងការរីកចម្រើននោះ។

វប្បធម៌វិទ្យារុស្ស៊ីបានកើតឡើង បន្ទាប់ពីការដួលរលំលទ្ធិម៉ាក្សនៅរុស្ស៊ី។ នៅតាមសាកលវិទ្យាល័យជាច្រើន ដេប៉ាតឺម៉ង់វប្បធម៌វិទ្យាបានចូលមកជំនួសទីកន្លែងដេប៉ាតឺម៉ង់លទ្ធិកុម្មុយនីស្តវិទ្យាសាស្ត្រនិងលទ្ធិម៉ាក្ស-លេនីន ដែលពីមុនដេប៉ាតឺម៉ង់នេះទទួលខុសត្រូវចំពោះចក្ខុវិស័យកំពូលខាងនយោបាយនិងការប្រើប្រាស់រាល់មុខវិជ្ជាផ្សេងទៀត។ គោលដៅចម្បងរបស់វប្បធម៌វិទ្យារុស្ស៊ី គឺផ្តាច់វប្បធម៌ចេញអំពីនយោបាយ ដោយមិនឱ្យវាជាឧបករណ៍អំណាច។

អ្នកប្រាជ្ញអាឡឺម៉ង់បានលើកឡើងថា ទស្សនវិជ្ជាជាមូលដ្ឋានរបស់វប្បធម៌វិទ្យា។ អ្នកប្រាជ្ញមួយចំនួនដូចជា *ហ្គេថេ* , *ហឺដឺ* , *វីនដែលបិន* , *ស៊ីមិល* និង *ស្ពិនលែរ* (Goethe, Herder, Windelband, Simmel និង

[១១] Wen-shan Huang, ***Culturology_Its Evolution and Prospects: An Integral Theory of Culture***, p. 19. (www.search.nioerar.edu.tw/edu_paper/data_image/g0000549/0n27/196901/p0000001.pdf)

Spengler) យល់ថា វប្បធម៌ជាអង្គសរីរាង្គរួម។ វប្បធម៌ក្តោបសកម្មភាពញាណនិងសកម្មភាពបង្កើតថ្មីផ្សេងៗ រួមមាន នយោបាយ សេដ្ឋកិច្ច វិទ្យាសាស្ត្រ សិល្បៈ អក្សរសាស្ត្រ ទស្សនវិជ្ជា និងសាសនា។

បច្ចុប្បន្ន វប្បធម៌វិទ្យា គឺជាមុខវិជ្ជាសិក្សាចាំបាច់មួយស្ទើរមិនអាចខានបាននៅឆ្នាំទី១ តាមសាកលវិទ្យាល័យ រួមមាន មហាវិទ្យាល័យវិទ្យាសាស្ត្រមនុស្ស មហាវិទ្យាល័យវិទ្យាសាស្ត្រធម្មជាតិនិងវិទ្យាសាស្ត្រពិត ច្បាប់ សេដ្ឋកិច្ច ពេទ្យ ឬបច្ចេកវិទ្យា។ ភាគច្រើន គេបង្រៀនវប្បធម៌វិទ្យានៅឆ្នាំទី២ ក្នុងលក្ខណៈជាការសិក្សាអំពីមូលដ្ឋានគ្រឹះនៃទស្សនវិជ្ជា។ នៅតាមសាកលវិទ្យាល័យជាច្រើន ជាពិសេសនៅសាកលវិទ្យាល័យតាមខេត្ត សាស្ត្រាចារ្យវប្បធម៌វិទ្យាជាអតីតសាស្ត្រាចារ្យទស្សនវិជ្ជា ដែលបង្រៀនលទ្ធិម៉ាក្ស រូបធាតុនិយមបដិសំយោគ ឬខ្លះបង្រៀនពីលទ្ធិបដិសេធអាទិទេព [១២] ។ គ្រូបង្រៀនវប្បធម៌វិទ្យាបានលេចឡើងជាលើកដំបូងនៅប្រទេសរុស្ស៊ីក្នុងទសវត្សឆ្នាំ១៩៨០ ហើយមួយទសវត្សក្រោយមក ទើបពួកគាត់បានក្លាយជាសាស្ត្រាចារ្យវប្បធម៌វិទ្យាពិតប្រាកដ។ នៅឆ្នាំ១៩៩៥ ក្រសួងអប់រំបានបង្កើតស្តង់ដាសញ្ញាបត្រជំនាញវប្បធម៌វិទ្យាជាលើកដំបូង ដែលតម្រូវឱ្យសិក្សារយៈពេលប្រាំឆ្នាំ។ ក្រោយមក គេបានបង្កើតថ្នាក់បណ្ឌិត ហើយនៅឆ្នាំ២០០០ គេមានថ្នាក់ក្រោយបណ្ឌិតជំនាញវប្បធម៌វិទ្យា។ ដោយមានការកំណត់ពីក្រសួង វប្បធម៌វិទ្យាផ្អែកលើការសិក្សាអំពីក្រុមមុខវិជ្ជាសេដ្ឋកិច្ចសង្គមនិងមុខវិជ្ជាមនុស្សសាស្ត្រ មុខវិជ្ជាវិទ្យាសាស្ត្រធម្មជាតិនិងវិទ្យាសាស្ត្រពិតនិងក្រុមមុខវិជ្ជាឯកទេសផ្សេងៗទៀតដែលបំពេញដោយថ្នាក់ឯកទេស មានសរសេរបើអត្ថបទ ការពារនិក្ខេបបទ និងមូលដ្ឋានអនុវត្តការបង្រៀន។ បច្ចុប្បន្ន ការសិក្សារយៈពេលប្រាំឆ្នាំពីមុន មានការកែប្រែមុខវិជ្ជាខ្លះ គឺមានវប្បធម៌វិទ្យាខ្លួនវា ប្រវត្តិសាសនា ប្រវត្តិសាស្ត្រជាតិនិងប្រវត្តិសាស្ត្រសាកលលោក ទស្សនវិជ្ជា សង្គមវិជ្ជា ចិត្តវិទ្យា ប្រវត្តិវិទ្យាសាស្ត្រ កុំព្យូទ័រ ភាសាបរទេស ភាសាវិទ្យា រូបសញ្ញាវិជ្ជា ការសិក្សាពីប្រពៃណីទំនៀមទម្លាប់អ្នកស្រុក ការសិក្សាពីសារមន្ទីរ ។ល។ ទៅតាមជម្រើសរបស់និស្សិត។ ឯកទេសនីយកម្មមុខវិជ្ជាវប្បធម៌វិទ្យា បាននាំឱ្យមានការបង្រៀនមុខវិជ្ជានេះនៅបឋមសិក្សានិងមធ្យមសិក្សានៅសហព័ន្ធរុស្ស៊ី។ [១៣]

បច្ចុប្បន្ន គ្រប់សាកលវិទ្យាល័យធំៗទាំងអស់នៅរុស្ស៊ីសុទ្ធសឹងមានមុខវិជ្ជាវប្បធម៌វិទ្យា ដែលផ្សារភ្ជាប់ទៅនឹងមុខវិជ្ជាផ្សេងទៀតតាមឯកទេសដើមរបស់អ្នកប្រាជ្ញវប្បធម៌វិទ្យាម្នាក់ៗ ដែលត្រូវចាត់តាំងឱ្យបម្រើតួនាទីនោះ ដូចជា ទស្សនវិជ្ជា ទ្រឹស្តីវប្បធម៌ គរុកោសល្យ ប្រវត្តិសាសនា ប្រវត្តិសិល្បៈ ភាសាបរទេស ការសិក្សាពីបូព៌ាប្រទេស ជាដើម។ មុខវិជ្ជាថ្មីនេះមានមុខងារផ្សេងៗជាច្រើន ហើយដែលសំខាន់នោះគឺជំនួសកន្លែងមុខវិជ្ជារូបធាតុនិយមបដិសំយោគនិងផ្តល់ទស្សនៈថ្មីអំពីអ្វីគួរជាវប្បធម៌ទូទៅនៅរុស្ស៊ី។ នៅកម្រិតខ្ពស់នៃមុខវិជ្ជានេះ គេហៅ *ទ្រឹស្តីអំពីវប្បធម៌* (Theories of culture) ជាជាង *វប្បធម៌វិទ្យា* [១៤] ។ ដូចនេះ រុស្ស៊ីប្រហែលជាប្រទេសដែលបង្កើតឱ្យមានការសិក្សាមុខវិជ្ជា *វប្បធម៌វិទ្យា* មុនគេ ហើយក្រោយមក គេឃើញមានការសិក្សាមុខវិជ្ជានេះមាននៅបណ្តាប្រទេសមួយចំនួនទៀត។ នៅអ៊ុយក្រែន ក្នុងអំឡុងទសវត្សឆ្នាំ១៩៩០ វប្បធម៌វិទ្យាបានក្លាយជាមុខវិជ្ជាវិទ្យាសាស្ត្រមួយដែលគេសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សានានា។ ដំបូងឡើយ វប្បធម៌វិទ្យាមានទម្រង់ជាការសិក្សារួមគ្នានៃសង្គមនិងវប្បធម៌។ ក្រោយមក វាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយមានកំណើននៃការ

---

[១២] ***Russian Culturology: Continuing Where Marxism Left Off***, (http://www.washprofile.org/ru/node /4862)

[១៣] Marlène Laruelle, ***The Discipline of Culturology: A New 'Ready-Made Thought' for Russia***, 2004. (www.sagepublications.com)

[១៤] Marlène Laruelle, ***The Discipline of Culturology: A New 'Ready-Made Thought' for Russia***, 2004. (www.sagepublications.com)

ចាប់អារម្មណ៍លើវប្បធម៌និងប្រវត្តិវប្បធម៌ ការរីកចម្រើនក្នុងទំនោរសាកលភាវូបនីយកម្ម និងការកើតឡើងនៃអរិយធម៌ក្រោយឧស្សាហកម្ម អរិយធម៌ពហុវប្បធម៌។ វប្បធម៌វិទ្យាសិក្សាពីការសម្តែងឡើងផ្សេងៗនៃវប្បធម៌កំពុងមានអត្តិភាព សិក្សាពីទំនាក់ទំនងរវាងបុគ្គលនិងសង្គម ពីស្នាដៃសម្រេចបាននិងបរាជ័យនៃវប្បធម៌បច្ចេកវិទ្យា ពីបម្រែបម្រួលនៃសោភ័ណវិជ្ជានិងសិល្បៈ ពីទំនាក់ទំនងរវាងជីវិតនិងសេចក្តីស្លាប់នៅក្នុងវប្បធម៌ផ្សេងៗ ភាពអាចប្រែប្រួលនៃគំរូទស្សនវិជ្ជានៅក្នុងប្រវត្តិវប្បធម៌ និងសិក្សាពីអ្វីៗផ្សេងទៀតជាច្រើន។ [១៥]

នៅឆ្នាំ២០០០ សាកលវិទ្យាល័យជាតិនៅទីក្រុងហូជីមិញ ប្រទេសវៀតណាម បានបើកវគ្គសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ខាងវប្បធម៌វិទ្យា ដែលជាវិទ្យាសាស្ត្រផ្តោតលើការសិក្សាស្រាវជ្រាវពីវប្បធម៌។ ក្រោយមក នៅឆ្នាំ២០០២ ទើបគេបង្កើតដេប៉ាតឺម៉ង់វប្បធម៌វិទ្យាជាផ្លូវការ ហើយបានក្លាយជាមហាវិទ្យាល័យវប្បធម៌វិទ្យាក្នុងឆ្នាំ២០០៨។ មហាវិទ្យាល័យវប្បធម៌វិទ្យាមានការសិក្សាកម្រិតបរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ កម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រវប្បធម៌វិទ្យាមានបំណងបណ្តុះបណ្តាលនិស្សិតឱ្យមានចំណេះដឹងខាងវប្ប-ធម៌ ប្រវត្តិវប្បធម៌ ភូមិសាស្ត្រវប្បធម៌ វប្បធម៌របស់ប្រជាជនជាតិពន្ធ និងមុខវិជ្ជាផ្សេងៗទៀតដែលទាក់ទងនឹងវប្បធម៌វៀតណាមនិងវប្បធម៌លើពិភពលោក។ កម្មវិធីបណ្តុះបណ្តាលនៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានភារកិច្ចបំពេញបន្ថែមនិងបង្កើនចំណេះដឹងនិស្សិតដែលទទួលបាននៅថ្នាក់បរិញ្ញាបត្រ ដោយធ្វើទំនើបកម្មចំណេះដោយឡែកៗនិងពង្រឹងការសិក្សាស្រាវជ្រាវ។ កម្មវិធីនេះក៏ផ្តោតលើចំណេះដឹងខាងវប្បធម៌ ប្រវត្តិវប្បធម៌ ភូមិសាស្ត្រវប្បធម៌របស់ប្រជាជនជាតិពន្ធ និងមុខវិជ្ជាផ្សេងៗទៀតដែលទាក់ទងនឹងវប្បធម៌វៀតណាមនិងវប្បធម៌លើពិភពលោកដែរ។ កម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិតផ្នែកវប្បធម៌វិទ្យាមានទិសដៅបណ្តុះបណ្តាលនិស្សិតខាងវប្បធម៌វិទ្យា ដោយពង្រឹងបន្ថែមការសិក្សាស្រាវជ្រាវអន្តរមុខវិជ្ជា ធ្វើទំនើបកម្មវិធីសាស្ត្រ និងសមត្ថភាពនៃការគិតបែបច្នៃប្រឌិត។ [១៦]

## សេចក្តីសន្និដ្ឋាន

វប្បធម៌វិទ្យាជាមុខវិជ្ជាសម្រាប់សិក្សាពីវប្បធម៌ អន្តរកម្មរវាងវប្បធម៌។ វាជួយយើងឱ្យសិក្សាបានស៊ីជម្រៅជាងមុខវិជ្ជាផ្សេងៗដែលសិក្សាអំពីវប្បធម៌ទៅតាមឯកទេសរៀងៗខ្លួន។ មុខវិជ្ជាផ្សេងៗមានកម្មវត្ថុសិក្សារបស់ខ្លួនច្បាស់លាស់ ដោយផ្តោតលើឯកទេសរបស់ខ្លួន ហេតុនេះការសិក្សារបស់មុខវិជ្ជាផ្សេងៗទៅលើវប្បធម៌ គឺគ្រាន់តែសិក្សាបាននូវចំណែកដោយឡែកៗនៃវប្បធម៌ប៉ុណ្ណោះ មិនសិក្សាបាននូវវប្បធម៌ទាំងមូលនោះទេ។ ប៉ុន្តែវប្បធម៌វិទ្យាមានកម្មវត្ថុសិក្សារបស់ខ្លួនគឺ វប្បធម៌ជា *ប្រព័ន្ធរួម* នៃវប្បធម៌និងជាតិសាសន៍ អាជីព ពូជសាសន៍ បញ្ញាភេទ ។ល។ ហេតុនេះវានឹងសិក្សាបាននូវវប្បធម៌ទាំងមូល។

យើងសង្កេតឃើញថា នៅប្រទេសរុស្ស៊ីដែលមានការបណ្តុះបណ្តាលមុខវិជ្ជាវប្បធម៌វិទ្យាជាប្រព័ន្ធ រហូតដល់មានការបណ្តុះបណ្តាលថ្នាក់ក្រោយបណ្ឌិតនោះ នៅដំណាក់កាលដំបូងនៃការចាប់ផ្តើមបង្កើតមុខវិជ្ជានេះគេបានប្រើសាស្ត្រាចារ្យឯកទេសទស្សនវិជ្ជា ដែលធ្លាប់បង្រៀនលទ្ធិម៉ាក្ស រូបធាតុនិយមបដិសំយោគ ឬបង្រៀនពីលទ្ធិបដិសេធអាទិទេព។ ចំណុចនេះបង្ហាញថា អ្នកឯកទេសទស្សនវិជ្ជាមានការពាក់ព័ន្ធនិងផ្សារភ្ជាប់យ៉ាងជិត

---

[១៥] Bohdan Shumylovych, ***Key Concepts and Terms of Culturology***, (http://www.lvivcenter.org/en/teaching/Shumylovych2011/)

[១៦] ***Faculty of Culturology***, (www.vanhoahoc.edu.vn)

ស្និទ្ធទៅនឹងមុខវិជ្ជាវប្បធម៌វិទ្យា ដោយវាបានផ្តល់ជាមូលដ្ឋាននៃការវិភាគអំពីវប្បធម៌។ វប្បធម៌វិទ្យាមិនត្រឹមតែសិក្សាពីឥរិយាបថមនុស្សនិងបាតុភូតផ្សេងៗក្នុងសង្គមមនុស្សប៉ុណ្ណោះទេ តែគឺវាសិក្សារកមូលហេតុដែលនាំឱ្យមនុស្សមានឥរិយាបថបែបនេះឬបែបនោះ និងមូលហេតុដែលនាំឱ្យមានបាតុភូតទាំងឡាយកើតមានឡើងក្នុងសង្គមទៀតផង ដែលនេះជាការពិចារណា វិភាគបែបទស្សនវិជ្ជាអំពីវប្បធម៌។

ទោះបីជាវប្បធម៌វិទ្យាជាមុខវិជ្ជាវិទ្យាសាស្ត្រសម្រាប់សិក្សាអង្កេតលើវប្បធម៌ក្តី តែក៏ទាមទារឱ្យមានជំនួយពីវិទ្យាសាស្ត្រដទៃទៀតដែរ ដើម្បីឱ្យការសិក្សាអង្កេតពីវប្បធម៌ដែលមានវិសាលភាពធំទូលាយនេះមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ ប៉ុន្តែ ដើម្បីចៀសវាងការភាន់ច្រឡំ វិទ្យាសាស្ត្រទាំងឡាយចាំបាច់ត្រូវដឹងនិងគោរពព្រំដែនរបស់ខ្លួនឱ្យបានត្រឹមត្រូវ។

## ឯកសារពិគ្រោះ


- ត្រឹង ងារ៖ ***អរិយធម៌ខ្មែរ*** (ថ្នាក់បញ្ចប់) បោះពុម្ពលើកទី៣ ភ្នំពេញ? ១៩៧៤។
- Akifumi Iwabuchi, ***Marine Culturology***, Tokyo University of Marine Science & Technology, 2010.( www.soi.wide.ad.jp/class/20090061/materials_for_student/03/20090061-03-2in1.pdf )
- Bohdan Shumylovych, ***Key Concepts and Terms of Culturology***, ( http://www. lvivcenter. org/en/teaching/Shumylovych2011/ )
- ***Culture***, ( http://en.wikipedia.org/wiki/Culture )
- ***Cultural Studies***, ( http://en.wikipedia.org/wiki/Cultural Studies )
- ***Culturology***, ( http://en.wikipedia.org/wiki/Culturology )
- ***Culturologists versus Philosophists ? Culturology versus Philososphy ?*** ( http://futurist guy.wordpress.com/2008/05/17/culturologists-versus-philosophists-culturology-versus-philosophy/ )
- ***Faculty of Culturology*** ( www.vanhoahoc.edu.vn )
- Leslie A. White, ***The Science of Culture: a study of man and civilization*** , New York, Grove Press, inc. 1949.
- Leslie A. White, ***Individuality and Individualism: A Culturological Interpretation***, The Universiy of Michigan, U.S.A. ( www.deepblue.lib.umich.edu/bitstream/2027.42/67052/2/10.1177_002071526300400104.pdf )
- Marlène Laruelle, ***The Discipline of Culturology: A New 'Ready-Made Thought' for Russia***, 2004. ( www.sagepublications. com )
- Mikhail Epstein, ***Culture - Culturology – Transculture***, ( http://www.emory.edu/INTELNET/af. culturology.html )

- Mikhail Epstein, ***From Culturology to Transculture***, ( http://books.google.com/books?isbn =03122 18087...
- ***POSITION PAPER, 2003, TRANSCULTURE***, ( http://arts.monash.edu.au/lcl/research/journals /trans-2003-epstien-position.pdf )
- ***Russian Culturology: Continuing Where Marxism Left Off***, ( www.washprofile.org/ru/node /4862 )
- Stephen P. Campodonico, ***Culturology: Using Organizational Culture for Strategic Growth***, 2012, ( www.culturologybook.com )
- Wen-shan Huang, ***Culturology_Its Evolution and Prospects: An Integral Theory of Culture***,( www.search.nioerar.edu.tw/edu_paper/data_image/g0000549/0n27/196901/p00 00001.pdf )